**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ...៤៤៣...សរ.ខល

# សេចក្តីជូនដំណឹង
# ស្តីពី
# លក្ខខណ្ឌធ្វើដំណើរ ការអនុវត្តវិធានសុខាភិបាល និងការធ្វើចត្តាឡីស័កនៅកម្ពុជាសម្រាប់អ្នកដំណើរចូលមកកម្ពុជា ស្របតាមគន្លងប្រក្រតីភាពថ្មី

តាមរយៈការដឹកនាំដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល លើការដាក់ចេញនូវ **យុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩**, កម្ពុជាកំពុងសម្រេចបាននូវអត្រានៃការចាក់វ៉ាក់សាំង លើសគោលដៅដែលបានគ្រោងទុក និងអាចបង្កើតបាននូវភាពស៊ាំសហគមន៍នៅទូទាំងកម្ពុជា ទប់ទល់នឹងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។ ជាមួយនឹងសមិទ្ធផលដ៏គួរជាទីមោទនភាពនេះ និងដោយមើលឃើញពីការវិវត្តកាន់តែប្រសើរឡើងនៃស្ថានភាពជាក់ស្តែង, រាជរដ្ឋាភិបាលកម្ពុជា សម្រេចបើកប្រទេសកម្ពុជាឡើងវិញជាបណ្តើរៗ និងតាមដំណាក់កាលជាមួយនឹងភាពប្រយ័ត្នប្រយែង និងការទទួលខុសត្រូវខ្ពស់ តាមគន្លងប្រក្រតីភាពថ្មី ដោយមានការសម្រួលរបបនៃការធ្វើចត្តាឡីស័ក សម្រាប់អ្នកដំណើរមកកម្ពុជា តាមគ្រប់ច្រកចូល **ដែលទទួលបានការចាក់វ៉ាក់សាំងដូសមូលដ្ឋានបានពេញលេញ** ដូចតទៅ៖

- **<u>ត្រូវអនុវត្តរបបពិសេស</u>** ទៅតាមការសម្រេចរបស់រាជរដ្ឋាភិបាល លើករណីនីមួយៗចំពោះភ្ញៀវផ្លូវការរបស់រាជរដ្ឋាភិបាល និងមន្ត្រីថ្នាក់ដឹកនាំជាន់ខ្ពស់របស់រាជរដ្ឋាភិបាល ដែលត្រលប់ពីបំពេញបេសកកម្មនៅក្រៅប្រទេស
- **<u>ត្រូវអនុវត្តរបបចត្តាឡីស័កចំនួន ៣ ថ្ងៃ</u>** ចំពោះវិនិយោគិន បុគ្គលិកជំនាញបច្ចេកទេសទាំងជនជាតិខ្មែរ និងបរទេស មន្ត្រីការទូត មន្ត្រីអនុវត្តគម្រោងសហប្រតិបត្តិការផ្លូវការ និងមន្ត្រីរាជការរបស់រាជរដ្ឋាភិបាលដែលត្រលប់មកពីបំពេញបេសកកម្មនៅក្រៅប្រទេស (ដោយរួមបញ្ចូលក្រុមគ្រួសាររបស់ក្រុម អាទិភាពនេះផង)
- **<u>ត្រូវអនុវត្តរបបចត្តាឡីស័កចំនួន ៧ ថ្ងៃ</u>** ចំពោះអ្នកដំណើរទូទៅដែលជាជនជាតិខ្មែរ ឬជនបរទេស និង

ដោយឡែក **<u>ត្រូវអនុវត្តរបបចត្តាឡីស័កចំនួន ១៤ ថ្ងៃ</u>** ចំពោះអ្នកដំណើរគ្រប់ប្រភេទដែល**មិនបានចាក់វ៉ាក់សាំងកូវីដ-១៩ ឬមិនទាន់បានចាក់វ៉ាក់សាំងដូសមូលដ្ឋានបានពេញលេញ**។

## ១.- ភ្ញៀវផ្លូវការរបស់រាជរដ្ឋាភិបាល និងមន្ត្រីថ្នាក់ដឹកនាំជាន់ខ្ពស់របស់រាជរដ្ឋាភិបាល ដែលត្រលប់ពីបំពេញបេសកកម្មនៅក្រៅប្រទេស

អ្នកដំណើរជាភ្ញៀវផ្លូវការរបស់រាជរដ្ឋាភិបាល និងមន្ត្រីថ្នាក់ដឹកនាំជាន់ខ្ពស់របស់រាជរដ្ឋាភិបាល ដែលត្រលប់ពីបំពេញបេសកកម្មនៅក្រៅប្រទេសត្រូវអនុវត្តវិធានសុខាភិបាល និងការធ្វើចត្តាឡីស័កពិសេសតាមការសម្រេចរបស់រាជរដ្ឋាភិបាលដោយផ្អែកតាមករណីនីមួយៗ។

បដិសេធ ឬឯកភាពអនុញ្ញាតដោយភ្ជាប់នូវលក្ខខណ្ឌ និងវិធានសុខាភិបាលសម្រាប់អ្នកដំណើរអនុវត្តដោយការទទួលខុសត្រូវខ្ពស់ចំពោះមុខច្បាប់នៃព្រះរាជាណាចក្រកម្ពុជាជាធរមាន។

## ៣.- មន្ត្រីការទូតបរទេស និងមន្ត្រីអនុវត្តគម្រោងសហប្រតិបត្តិការផ្លូវការ និងក្រុមគ្រួសារ

ចំពោះមន្ត្រីការទូតបរទេស និងមន្ត្រីអនុវត្តគម្រោងសហប្រតិបត្តិការផ្លូវការ ដែលកាន់ទិដ្ឋាការការទូត (Visa A) និងទិដ្ឋាការផ្លូវការ (Visa B) និងក្រុមគ្រួសារ ត្រូវអនុវត្ត ដូចខាងក្រោម៖

- ត្រូវអនុវត្តវិធានការចត្តាឡីស័កចំនួន **៣ថ្ងៃ** ក្នុងករណីបានចាក់វ៉ាក់សាំងពេញលេញ ឬ **១៤ថ្ងៃ** ក្នុងករណីមិនបានចាក់វ៉ាក់សាំង ឬចាក់វ៉ាក់សាំងមិនទាន់ពេញលេញ
- ត្រូវមានបណ្ណ ឬវិញ្ញាបនបត្រចាក់វ៉ាក់សាំងកូវីដ-១៩ ដែលបញ្ជាក់ពីការចាក់វ៉ាក់សាំងពេញលេញ ប្រភេទវ៉ាក់សាំង និងកាលបរិច្ឆេទនៃការចាក់វ៉ាក់សាំង
- ត្រូវមានវិញ្ញាបនបត្របញ្ជាក់ថាគ្មានជំងឺកូវីដ-១៩ ក្នុងរយៈពេល ៧២ ម៉ោង មុនពេលមកដល់កម្ពុជា ទទួលស្គាល់ដោយអាជ្ញាធរសុខាភិបាលនៃប្រទេសសាមី
- អាចស្នាក់នៅនិវេសនដ្ឋានរបស់ស្ថានទូត ឬគេហដ្ឋានដាច់ដោយឡែក ដូចមានបញ្ជាក់ក្នុងលិខិតលេខ ៣៤៣ សខល ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១ របស់ក្រសួងសុខាភិបាល ឬសណ្ឋាគារដែលអាចទទួលកក់បាន (ដូចមានបង្ហាញក្នុងឧបសម្ព័ន្ធទី ១) ដើម្បីធ្វើចត្តាឡីស័ក **៣ថ្ងៃ** ឬ **១៤ថ្ងៃ** ពេញលេញ និង ស្ថិតក្រោមការត្រួតពិនិត្យរបស់ស្ថានទូត អង្គការអន្តរជាតិសាមី និងមន្ត្រីសុខាភិបាល ដោយចំណាយទាំងអស់ជាបន្ទុករបស់សាមីខ្លួនផ្ទាល់។
- ក្នុងអំឡុងពេលធ្វើចត្តាឡីស័ក អ្នកដែលត្រូវធ្វើចត្តាឡីស័កមិនត្រូវបានអនុញ្ញាតឱ្យជួបភ្ញៀវ ឬចាកចេញពីទីតាំង ឬបន្ទប់ចត្តាឡីស័កឡើយ ហើយត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានសុខាភិបាលនានា ដែលបានដាក់ចេញដោយក្រសួងសុខាភិបាល
- ការធ្វើដំណើរចេញពីច្រកទ្វារចេញ-ចូលប្រទេស ឆ្ពោះទៅកាន់និវេសនដ្ឋានរបស់ស្ថានទូត ឬគេហដ្ឋានដាច់ដោយឡែក ត្រូវប្រើប្រាស់តែមធ្យោបាយដឹកជញ្ជូនរបស់ស្ថានទូត ឬអង្គការអន្តរជាតិ។ ចំពោះការធ្វើដំណើរទៅសណ្ឋាគារដូចបានរៀបរាប់ខាងលើ ត្រូវប្រើប្រាស់តែមធ្យោបាយដឹកជញ្ជូនរបស់សណ្ឋាគារ ដែលបានកក់ហើយតែប៉ុណ្ណោះ
- ត្រូវធ្វើតេស្តទាំងអស់ ពេលមកដល់កម្ពុជា ហើយសំណាកត្រូវយកនៅទីតាំងពិសេសក្នុងស្ថានីយមកដល់របស់អ្នកដំណើរតែម្តង
- ក្នុងករណីមានការរកឃើញវីរុសកូវីដ-១៩ វិជ្ជមាន បញ្ជាក់ដោយមន្ទីរពិសោធន៍ អ្នកជំងឺត្រូវបញ្ជូនទៅកាន់ទីតាំងព្យាបាលដែលស្ថានទូត ឬអង្គការអន្តរជាតិសំណូមពរ ហើយដែលក្រសួងសុខាភិបាលឯកភាព ដើម្បីធ្វើការព្យាបាល។ រាល់ការ សម្រាកព្យាបាលជាបន្ទុករបស់មន្ត្រីការទូត ឬស្ថានទូត និងអង្គការអន្តរជាតិផ្ទាល់។



ចូលរួមគ្រប់ព័ត៌មាន | JOIN US

## ៤.- អ្នកដំណើរបរទេសដែលជាវិនិយោគិន បុគ្គលិកជំនាញបច្ចេកទេស និងក្រុមគ្រួសារ ដែលមានការធានា ឬការអញ្ជើញ

### ៤.១.-យន្តការនៃការធានា ឬការអញ្ជើញ

អ្នកដំណើរបរទេសអាចជា **វិនិយោគិន បុគ្គលិកជំនាញបច្ចេកទេស និងក្រុមគ្រួសារ។** ដើម្បីទទួលបានទិដ្ឋាការចូលមកកម្ពុជាអ្នកទាំងនោះត្រូវមានការធានា ឬការអញ្ជើញពីដៃគូក្នុងស្រុក ដែលជានីតិបុគ្គលស្របច្បាប់ មានការចុះបញ្ជី និងបង់ពន្ធត្រឹមត្រូវនៅកម្ពុជា។ យន្តការនៃការធានា និងការអញ្ជើញនេះ ត្រូវធ្វើលើថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) តាមរយៈគេហទំព័រ www.registrationservices.gov.kh ដោយភ្ជាប់នូវព័ត៌មាន ដូចខាងក្រោម៖

- ព័ត៌មានរបស់ក្រុមហ៊ុន ជាអាទិ៍ ឈ្មោះក្រុមហ៊ុន លេខវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម លេខគម្រោងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ឬលេខអត្តសញ្ញាណកម្មសារពើពន្ធ លេខទំនាក់ទំនង អាសយដ្ឋាន អ៊ីម៉ែល
- ព័ត៌មានរបស់អ្នកធានា ឬអ្នកអញ្ជើញ ជាអាទិ៍ ឈ្មោះ ថ្ងៃខែឆ្នាំកំណើត លេខទំនាក់ទំនង លេខលិខិតឆ្លងដែន ឬលេខអត្តសញ្ញាណប័ណ្ណ
- ព័ត៌មានរបស់អ្នកដំណើរ ជាអាទិ៍ ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត ទំនាក់ទំនងជាមួយអ្នកធានា លេខទំនាក់ទំនង លេខលិខិតឆ្លងដែន លេខបណ្ណការងារ (បើមាន) សញ្ជាតិ រយៈពេលស្នាក់នៅកម្ពុជា វត្ថុបំណងនៃការធ្វើដំណើរមកកាន់ប្រទេសកម្ពុជា និងព័ត៌មាននៃការចាក់វ៉ាក់សាំង។ ក្នុងករណីមានបណ្ណការងារ អ្នកស្នើសុំអាចបំពេញលេខសម្គាល់បណ្ណការងារ និងថ្ងៃខែឆ្នាំកំណើតរបស់អ្នកដំណើរ, នោះព័ត៌មានរបស់អ្នកដំណើរនោះនឹងបំពេញដោយស្វ័យប្រវត្តិលើពាក្យស្នើសុំ តាមរយៈការផ្លាស់ប្តូរទិន្នន័យលើថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX)។

ក្នុងរយៈពេលយ៉ាងយូរ **៣(បី)ថ្ងៃនៃថ្ងៃធ្វើការ** អ្នកស្នើសុំនឹងទទួលបាននូវការឆ្លើយតបដូចខាងក្រោម៖

- ក្នុងករណីមិនឯកភាព អ្នកស្នើសុំនឹងទទួលបាននូវមូលហេតុជាក់លាក់មួយ ដែលអាចធ្វើការកែតម្រូវ និងធ្វើការស្នើសុំម្តងទៀត
- ក្នុងករណីឯកភាព អ្នកស្នើសុំនឹងទទួលបានលិខិតបញ្ជាក់លើការធានា ឬលិខិតបញ្ជាក់លើការអញ្ជើញ តាមការស្នើសុំ។

**លិខិតបញ្ជាក់លើការធានា៖** ជាលិខិតដែលបញ្ជាក់ថា អ្នកស្នើសុំដែលជាអ្នកធានា គឺជាអ្នកទទួលខុសត្រូវទាំងស្រុងលើចំណាយទាំងអស់ពាក់ព័ន្ធនឹងការធ្វើចត្តាឡីស័ក និង/ឬ ការព្យាបាល ក្នុងករណីដែលអ្នកដំណើរមានការឆ្លងជំងឺកូវីដ-១៩ ក្នុងអំឡុងពេលធ្វើចត្តាឡីស័កនិងស្នាក់នៅកម្ពុជា។

**លិខិតបញ្ជាក់លើការអញ្ជើញ៖** ជាលិខិតដែលបញ្ជាក់ថា អ្នកដំណើរគឺជាអ្នកទទួលខុសត្រូវទាំងស្រុងលើចំណាយទាំងអស់ដោយខ្លួនឯង។

លិខិតបញ្ជាក់ទាំងពីរប្រភេទខាងលើ ដូចមានបង្ហាញគំរូក្នុងឧបសម្ព័ន្ធទី ២ និងទី ៣ មានសុពលភាព ៣០ ថ្ងៃ ដែលអាចប្រើប្រាស់បានតែ ១ដងគត់ និងមានទម្រង់ឌីជីថល ដែលអ្នកដំណើរអាចទាញយក និងបោះពុម្ពបានដោយខ្លួនឯង តាមគេហទំព័រខាងលើ។

### ៤.២.-លក្ខខណ្ឌធ្វើដំណើរ

**មុនពេលធ្វើដំណើរមកកម្ពុជា** អ្នកដំណើរបរទេសត្រូវត្រៀមរៀបចំឱ្យរួចរាល់ ដើម្បីបំពេញលក្ខខណ្ឌតម្រូវសំខាន់ៗ ដូចខាងក្រោម៖

- ត្រូវអនុវត្តវិធានការចត្តាឡីស័កចំនួន **៣ថ្ងៃ** ក្នុងករណីបានចាក់វ៉ាក់សាំងពេញលេញ ឬ **១៤ថ្ងៃ** ក្នុងករណីមិនបានចាក់វ៉ាក់សាំង ឬចាក់វ៉ាក់សាំងមិនទាន់ពេញលេញ
- ក្នុងករណីអ្នកដំណើរជាបុគ្គលិកក្រុមហ៊ុន អ្នកជំនាញ ឬអ្នកអញ្ជើញត្រូវធ្វើការស្នើសុំបណ្ណការងាររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈគេហទំព័រ https://www.fwcms.mlvt.gov.kh/ មុនការស្នើសុំលិខិតបញ្ជាក់លើការធានា ឬលិខិតបញ្ជាក់លើការអញ្ជើញ
- ក្នុងករណីត្រូវការទិដ្ឋាការដើម្បីធ្វើដំណើរមកកម្ពុជា, អ្នកដំណើរត្រូវស្នើសុំទិដ្ឋាការដែលមានសុពលភាពស្របតាមនីតិវិធីនៃច្បាប់ស្តីពីអន្តោប្រវេសន៍ ពីសំណាក់ស្ថានទូតកម្ពុជា ឬពីស្ថានកុងស៊ុលកម្ពុជា។ ការស្នើសុំទិដ្ឋាការត្រូវធ្វើឡើងមុនចេញដំណើរមកកម្ពុជា **ដោយរាជរដ្ឋាភិបាលកម្ពុជា មិនទាន់អនុញ្ញាតឱ្យមានទិដ្ឋាការនៅពេលមកដល់ (Visa on Arrival) នៅឡើយ**។ អ្នកដំណើរដែលកាន់លិខិតឆ្លងដែននៃប្រទេសដែលមិនតម្រូវឱ្យស្នើសុំទិដ្ឋាការ អាចធ្វើដំណើរមកកម្ពុជា ដោយមិនចាំបាច់ស្នើសុំទិដ្ឋាការទេ
- លិខិតបញ្ជាក់លើការធានា ឬលិខិតបញ្ជាក់លើការអញ្ជើញ ត្រូវធ្វើឱ្យបានរួចរាល់ មុនចូលមកដល់កម្ពុជា
- វិញ្ញាបនបត្របញ្ជាក់ថាគ្មានជំងឺកូវីដ-១៩ ក្នុងរយៈពេល ៧២ ម៉ោង មុនពេលមកដល់កម្ពុជា ទទួលស្គាល់ដោយអាជ្ញាធរសុខាភិបាលនៃប្រទេសសាមី
- បណ្ណ ឬវិញ្ញាបនបត្រចាក់វ៉ាក់សាំងកូវីដ-១៩ ដែលបញ្ជាក់ពីការចាក់វ៉ាក់សាំងពេញលេញ ប្រភេទវ៉ាក់សាំង និងកាលបរិច្ឆេទនៃការចាក់វ៉ាក់សាំង
- ឯកសារកក់សណ្ឋាគារសម្រាប់ការធ្វើចត្តាឡីស័ក **នៅសណ្ឋាគារណាមួយ (ដូចមានបង្ហាញក្នុងឧបសម្ព័ន្ធទី ១)**។ ក្នុងករណីពុំមាន ត្រូវត្រៀមសាច់ប្រាក់ចំនួន ៦០០ ដុល្លារអាមេរិក ដើម្បីតម្កល់នៅច្រកចូលកម្ពុជា សម្រាប់ជានាចំណាយទាំងអស់ពាក់ព័ន្ធនឹងការធ្វើចត្តាឡីស័ក ក្នុងអំឡុងពេលធ្វើចត្តាឡីស័កនៅពេលមកដល់កម្ពុជា។
- បណ្ណសន្យារ៉ាប់រងសុខភាពសម្រាប់ព្យាបាលជំងឺកូវីដ-១៩ (Covid-19 Health Insurance Policy) ដែលជាការធានារ៉ាប់រងរួមគ្នា (Insurance consortium) ដោយក្រុមហ៊ុនធានារ៉ាប់រងមួយចំនួននៅកម្ពុជា៖ ត្រូវទិញធានារ៉ាប់រងសុខភាពសម្រាប់ព្យាបាលជំងឺកូវីដ-១៩ ពីក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ ដែលជាក្រុមហ៊ុនតំណាងឱ្យការធានារ៉ាប់រងរួមគ្នា តាមរយៈគេហទំព័រ https://www.forteinsurance.com/covid-19-insurance/។

**ពេលមកដល់ច្រកទ្វារចេញ-ចូលប្រទេសកម្ពុជា** អ្នកដំណើរបរទេស ត្រូវបង្ហាញគ្រប់ឯកសារ ដែលរៀបរាប់ខាងលើ។ អាជ្ញាធរមានសមត្ថកិច្ច នឹងស្កែន QR Code លើលិខិតបញ្ជាក់លើការធានា ឬលិខិតបញ្ជាក់លើការអញ្ជើញរបស់អ្នកដំណើរ ដើម្បីធានាភាពពិតប្រាកដនៃឯកសារនេះ។

**៤.៣.-ការអនុវត្តវិធានសុខាភិបាល នៅពេលមកដល់កម្ពុជា**

**ករណីទូទៅ៖** បន្ទាប់ពីបានបំពេញគ្រប់លក្ខខណ្ឌក្នុងចំណុច ៤.២ ខាងលើ អ្នកដំណើរនឹងត្រូវបានពិនិត្យសុខភាព និងយកសំណាកដោយមន្ត្រីសុខាភិបាល មុននឹងត្រូវបញ្ជូនទៅសណ្ឋាគារ ឬទីតាំងដែលកំណត់ដោយក្រសួងសុខាភិបាល ដើម្បីធ្វើចត្តាឡីស័ក។ ក្រោយពេលទៅដល់ទីតាំងចត្តាឡីស័កនៅសណ្ឋាគារ ឬទីតាំងដែលកំណត់ដោយក្រសួងសុខាភិបាល អ្នកដំណើរនឹងត្រូវរង់ចាំលទ្ធផលតេស្ត។

- ក្នុងករណីលទ្ធផលតេស្តម៉ាស៊ីន PCR បញ្ជាក់ថា វិជ្ជមានកូវីដ-១៩ អ្នកដំណើរនឹងត្រូវបញ្ជូនទៅព្យាបាលនៅតាមមណ្ឌលព្យាបាល
- ក្នុងករណីលទ្ធផលតេស្តម៉ាស៊ីន PCR បញ្ជាក់ថា អវិជ្ជមានកូវីដ-១៩ អ្នកដំណើរនឹងត្រូវបញ្ចប់ការធ្វើចត្តាឡីស័ក **នៅថ្ងៃទី៣**។

**ករណីពិសេស៖** ក្នុងករណីចាំបាច់ដែលអ្នកដំណើរខាងលើមិនអាចធ្វើចត្តាឡីស័កពេញលេញ អ្នកធានា ឬអ្នកអញ្ជើញ ត្រូវដាក់លិខិតស្នើសុំទៅអនុគណៈកម្មការទី២ ជាមុន ដើម្បីស្នើសុំគោលការណ៍ពិសេសសម្រាប់ការធ្វើចត្តាឡីស័ករយៈពេលខ្លី។ អ្នកធានា ឬអ្នកអញ្ជើញ ត្រូវបង្ហាញពីហេតុផល និងភាពចាំបាច់នៃការធ្វើចត្តាឡីស័ករយៈពេលខ្លី រួមទាំងកម្មវិធីលម្អិតនៃការធ្វើដំណើរមកកម្ពុជា។ ក្រោយពីពិនិត្យលើការស្នើសុំ អនុគណៈកម្មការទី២ អាចបដិសេធដោយភ្ជាប់នូវហេតុផល ឬឯកភាពអនុញ្ញាតដោយភ្ជាប់នូវលក្ខខណ្ឌ និងវិធានសុខាភិបាលពិសេស សម្រាប់អ្នកដំណើរ និងអ្នកធានាអនុវត្ត ដោយការទទួលខុសត្រូវខ្ពស់ចំពោះមុខច្បាប់នៃព្រះរាជាណាចក្រកម្ពុជាជាធរមាន។

## ៥.- អ្នកដំណើរទូទៅជាជនជាតិខ្មែរ ឬជនបរទេស

### ៥.១.-អ្នកដំណើរទូទៅជាជនជាតិខ្មែរ

អ្នកដំណើរទូទៅជាជនជាតិខ្មែរ សំដៅដល់ជនជាតិខ្មែរ ដែលកាន់លិខិតឆ្លងដែនខ្មែរ ឬកាន់លិខិតឆ្លងដែនបរទេស ប៉ុន្តែមានទិដ្ឋាការប្រភេទ K ។

#### ក.-លក្ខខណ្ឌធ្វើដំណើរ

**មុនពេលធ្វើដំណើរមកដល់កម្ពុជា** អ្នកដំណើរត្រូវត្រៀមឱ្យរួចរាល់នូវឯកសារ ដូចខាងក្រោម៖

- វិញ្ញាបនបត្របញ្ជាក់ថាគ្មានជំងឺកូវីដ-១៩ ក្នុងរយៈពេល ៧២ ម៉ោង មុនពេលមកដល់កម្ពុជា ទទួលស្គាល់ដោយអាជ្ញាធរសុខាភិបាលនៃប្រទេសសាមី
- ត្រូវមានបណ្ណ ឬវិញ្ញាបនបត្រចាក់វ៉ាក់សាំងកូវីដ-១៩ ដែលបញ្ជាក់ពីការចាក់វ៉ាក់សាំងពេញលេញ ប្រភេទវ៉ាក់សាំងនិងកាលបរិច្ឆេទនៃការចាក់វ៉ាក់សាំង
- ទិដ្ឋាការប្រភេទ K ក្នុងករណីអ្នកដំណើរជាជនជាតិខ្មែរកាន់លិខិតឆ្លងដែនបរទេស។ ការស្នើសុំទិដ្ឋាការត្រូវធ្វើឡើងមុនចេញដំណើរមកកម្ពុជា **ដោយរាជរដ្ឋាភិបាលកម្ពុជា មិនទាន់អនុញ្ញាតឱ្យមានទិដ្ឋាការនៅពេលមកដល់ (Visa on Arrival) នៅឡើយ**។ អ្នកដំណើរដែលកាន់លិខិតឆ្លងដែននៃប្រទេសដែលមិនតម្រូវឱ្យស្នើសុំទិដ្ឋាការ អាចធ្វើដំណើរមកកម្ពុជា ដោយមិនចាំបាច់ស្នើសុំទិដ្ឋាការទេ
- ឯកសារបញ្ជាក់ការកក់សណ្ឋាគារ ក្នុងករណីអ្នកដំណើរចង់ធ្វើចត្តាឡីស័កនៅសណ្ឋាគារ ដែលទទួលសេវាកក់តាមអនឡាញ (ដូចមានបង្ហាញក្នុងឧបសម្ព័ន្ធទី ១) ។

**ពេលមកដល់ច្រកទ្វារចេញ-ចូលប្រទេសកម្ពុជា** អ្នកដំណើរត្រូវបង្ហាញគ្រប់ឯកសារពាក់ព័ន្ធខាងលើ។

#### ខ.-ការអនុវត្តវិធានសុខាភិបាល

បន្ទាប់ពីទទួលបានការត្រួតពិនិត្យឯកសារតម្រូវដូចខាងលើ អ្នកដំណើរនឹងត្រូវបានពិនិត្យសុខភាព និងយកសំណាកដោយមន្ត្រីសុខាភិបាល មុននឹងត្រូវបញ្ជូនទៅសណ្ឋាគារ ឬទីតាំងដែលកំណត់ដោយក្រសួងសុខាភិបាល ដើម្បីធ្វើចត្តាឡីស័ក។

- ក្នុងករណីអ្នកដំណើរគ្មានលទ្ធភាពបង់ថ្លៃសេវាចត្តាឡីស័កនៅសណ្ឋាគារ អ្នកដំណើរត្រូវទៅធ្វើចត្តាឡីស័កនៅតាមទីតាំង និងគោរពតាមលក្ខខណ្ឌ ដែលកំណត់ដោយក្រសួងសុខាភិបាល ហើយរាល់ចំណាយត្រូវធានាដោយថវិការដ្ឋ
- ក្នុងករណីអ្នកដំណើរមានលទ្ធភាពបង់ថ្លៃសេវាចត្តាឡីស័កនៅសណ្ឋាគារដោយខ្លួនឯង មន្ត្រីសម្រប-សម្រួលនៅតាមច្រកទ្វារចេញ-ចូលប្រទេស នឹងរៀបចំឱ្យអ្នកដំណើរបានទៅធ្វើចត្តាឡីស័កនៅសណ្ឋាគារ បន្ទាប់ពីបានយកសំណាករួចរាល់។

ក្រោយពេលទៅដល់ទីតាំងចត្តាឡីស័កនៅសណ្ឋាគារ ឬទីតាំងដែលកំណត់ដោយក្រសួងសុខាភិបាល អ្នកដំណើរនឹងត្រូវរង់ចាំលទ្ធផល។

- ក្នុងករណីលទ្ធផលតេស្តលើកទី១ ដោយប្រើ Rapid Test (នៅពេលមកដល់កម្ពុជា) វិជ្ជមានកូវីដ-១៩ អ្នកដំណើរនឹងត្រូវបញ្ជូនទៅព្យាបាលនៅតាមមណ្ឌលព្យាបាល
- ក្នុងករណីលទ្ធផលតេស្តលើកទី១ ដោយប្រើ Rapid Test អវិជ្ជមានកូវីដ-១៩ អ្នកដំណើរត្រូវបន្តធ្វើចត្តាឡីស័ករយៈពេលចំនួន **៧ថ្ងៃ** ហើយអ្នកដំណើរត្រូវទទួលការយកសំណាកលើកទី២ ដោយធ្វើតេស្តដោយម៉ាស៊ីន PCR នៅថ្ងៃទី៦។ ក្នុងករណីលទ្ធផលបញ្ជាក់ថា វិជ្ជមានកូវីដ-១៩ ត្រូវបញ្ជូនទៅព្យាបាល។ ក្នុងករណីលទ្ធផលបញ្ជាក់ថា អវិជ្ជមានកូវីដ-១៩ ត្រូវបញ្ចប់ការធ្វើចត្តាឡីស័ក នៅថ្ងៃទី៧។

ក្នុងករណីគេហដ្ឋានរបស់របស់អ្នកដំណើរជាជនជាតិខ្មែរខាងលើ មានភាពសមស្របដល់ការធ្វើចត្តាឡីស័កស្របតាមវិធានការចត្តាឡីស័កនៅផ្ទះ៖ អ្នកដំណើរអាចស្នើសុំមកអនុគណៈកម្មការគ្រប់គ្រងច្រកទ្វារចេញ-ចូលប្រទេស និងការធ្វើចត្តាឡីស័ក (អនុគណៈកម្មការទី២) យ៉ាងតិច ៣ ថ្ងៃនៃថ្ងៃធ្វើការ មុនពេលមកដល់កម្ពុជា ដើម្បីធ្វើចត្តាឡីស័កនៅផ្ទះ។ ក្រោយពីពិនិត្យលើការស្នើសុំ អនុគណៈកម្មការទី២ អាចបដិសេធ ឬឯកភាពអនុញ្ញាតដោយភ្ជាប់នូវលក្ខខណ្ឌ និងវិធានសុខាភិបាលសម្រាប់អ្នកដំណើរអនុវត្តដោយការទទួលខុសត្រូវខ្ពស់ចំពោះមុខច្បាប់នៃព្រះរាជាណាចក្រកម្ពុជាជាធរមាន។

**កំណត់សម្គាល់៖** អ្នកដំណើរជនជាតិខ្មែរ ដែលជា **វិនិយោគិន បុគ្គលិកជំនាញបច្ចេកទេស និងក្រុមគ្រួសារ** និងមានការធានា ឬការអញ្ជើញពីដៃគូក្នុងស្រុក ដែលជានីតិបុគ្គលស្របច្បាប់ មានការចុះបញ្ជី និងបង់ពន្ធត្រឹមត្រូវនៅកម្ពុជា ក៏អាចធ្វើការស្នើលិខិតបញ្ជាក់លើការធានា ឬការអញ្ជើញ តាមយន្តការ ដែលបានរៀបរាប់នៅចំណុចទី ៤.១ ខាងលើដែរ ដើម្បីទទួលបានការធ្វើចត្តាឡីស័កចំនួន **៣ថ្ងៃ**។

### ៥.២.-អ្នកដំណើរទូទៅជាជនបរទេស

អ្នកដំណើរទូទៅជាជនបរទេស សំដៅដល់អ្នកដំណើរបរទេសទូទៅ ដោយរាប់បញ្ចូលទាំងអ្នកទេសចរ និងវិនិយោគិន បុគ្គលិកជំនាញបច្ចេកទេស និងក្រុមគ្រួសារ ដែលមិនមានការធានា ឬការអញ្ជើញ។

#### ក.-លក្ខខណ្ឌធ្វើដំណើរ

**មុនពេលធ្វើដំណើរមកដល់កម្ពុជា** អ្នកដំណើរបរទេសត្រូវត្រៀមឱ្យរួចរាល់នូវឯកសារ ដូចខាងក្រោម៖

- វិញ្ញាបនបត្របញ្ជាក់ថាគ្មានជំងឺកូវីដ-១៩ ក្នុងរយៈពេល ៧២ ម៉ោង មុនពេលមកដល់កម្ពុជា ទទួលស្គាល់ដោយអាជ្ញាធរសុខាភិបាលនៃប្រទេសសាមី
- ត្រូវមានបណ្ណ ឬវិញ្ញាបនបត្រចាក់វ៉ាក់សាំងកូវីដ-១៩ ដែលបញ្ជាក់ពីការចាក់វ៉ាក់សាំងពេញលេញ ប្រភេទវ៉ាក់សាំងនិងកាលបរិច្ឆេទនៃការចាក់វ៉ាក់សាំង

- ក្នុងករណីត្រូវការទិដ្ឋាការដើម្បីធ្វើដំណើរមកកម្ពុជា អ្នកដំណើរត្រូវស្នើសុំទិដ្ឋាការដែលមានសុពលភាពស្របតាមនីតិវិធីនៃច្បាប់ស្ដីពីអន្តោប្រវេសន៍ ពីសំណាក់ស្ថានទូតកម្ពុជា ឬពីស្ថានកុងស៊ុលកម្ពុជា ។ ការស្នើសុំទិដ្ឋាការត្រូវធ្វើឡើងមុនចេញដំណើរមកកម្ពុជា **ដោយរាជរដ្ឋាភិបាលកម្ពុជាមិនទាន់អនុញ្ញាតឱ្យមានទិដ្ឋាការនៅពេលមកដល់ (Visa on Arrival) នៅឡើយ**។ អ្នកដំណើរដែលកាន់លិខិតឆ្លងដែននៃប្រទេសដែលមិនតម្រូវឱ្យស្នើសុំទិដ្ឋាការ អាចធ្វើដំណើរមកកម្ពុជា ដោយមិនចាំបាច់ស្នើសុំទិដ្ឋាការទេ
- ក្នុងករណីអ្នកដំណើរបរទេសជាបុគ្គលិក ដែលត្រូវបម្រើការងារនៅក្រុមហ៊ុនមានមូលដ្ឋាននៅព្រះរាជាណាចក្រកម្ពុជា ហើយបណ្ណការងារអស់សុពលភាព ឬមិនទាន់មាន, អ្នកដំណើរបរទេសត្រូវធ្វើការស្នើសុំបណ្ណការងាររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈគេហទំព័រ https://www.fwcms.mlvt.gov.kh/
- ឯកសារកក់សណ្ឋាគារសម្រាប់ការធ្វើចត្តាឡីស័ក **នៅសណ្ឋាគារណាមួយ (ដូចមានបង្ហាញក្នុងឧបសម្ព័ន្ធទី ១)**។ ក្នុងករណីពុំមាន ត្រូវត្រៀមសាច់ប្រាក់ចំនួន ១ ០០០ ដុល្លារអាមេរិក ដើម្បីតម្កល់នៅច្រកចូលកម្ពុជា សម្រាប់ធានាចំណាយទាំងអស់ពាក់ព័ន្ធនឹងការធ្វើចត្តាឡីស័ក ក្នុងអំឡុងពេលធ្វើចត្តាឡីស័កនៅពេលមកដល់កម្ពុជា។
- បណ្ណសន្យារ៉ាប់រងសុខភាពសម្រាប់ព្យាបាលជំងឺកូវីដ-១៩ (Covid-19 Health Insurance Policy) ដែលជាការធានារ៉ាប់រងរួមគ្នា (Insurance consortium) ដោយក្រុមហ៊ុនធានារ៉ាប់រងមួយចំនួននៅកម្ពុជា៖ ត្រូវទិញធានារ៉ាប់រងសុខភាពសម្រាប់ព្យាបាលជំងឺកូវីដ-១៩ ពីក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ ដែលជាក្រុមហ៊ុនតំណាងឱ្យការធានារ៉ាប់រងរួមគ្នា តាមរយៈគេហទំព័រ https://www.forteinsurance.com/covid-19-insurance/។

**ពេលមកដល់ច្រកទ្វារចេញ-ចូលប្រទេសកម្ពុជា** អ្នកដំណើរបរទេស ត្រូវបង្ហាញគ្រប់ឯកសារ ដែលរៀបរាប់ខាងលើ ។

**ខ.-ការអនុវត្តវិធានសុខាភិបាល**

បន្ទាប់ពីទទួលបានការត្រួតពិនិត្យឯកសារតម្រូវដូចខាងលើ អ្នកដំណើរបរទេសនឹងត្រូវបានពិនិត្យសុខភាព និងយកសំណាកដោយមន្ត្រីសុខាភិបាល មុននឹងត្រូវបញ្ជូនទៅសណ្ឋាគារ ឬទីតាំងដែលកំណត់ដោយក្រសួងសុខាភិបាល ដើម្បីធ្វើចត្តាឡីស័ក ក្នុងរយៈពេល **៧ថ្ងៃ**។

ក្រោយពេលទៅដល់ទីតាំងចត្តាឡីស័កនៅសណ្ឋាគារ ឬទីតាំងដែលកំណត់ដោយក្រសួងសុខាភិបាល អ្នកដំណើរបរទេសនឹងត្រូវរង់ចាំលទ្ធផល៖

- ក្នុងករណីលទ្ធផលតេស្តលើកទី១ ដោយប្រើ Rapid Test (នៅពេលមកដល់កម្ពុជា) វិជ្ជមានកូវីដ-១៩ អ្នកដំណើរបរទេសនឹងត្រូវបញ្ជូនទៅព្យាបាលនៅតាមមណ្ឌលព្យាបាល
- ក្នុងករណីលទ្ធផលតេស្តលើកទី១ ដោយប្រើ Rapid Test អវិជ្ជមានកូវីដ-១៩ អ្នកដំណើរបរទេសត្រូវបន្តធ្វើចត្តាឡីស័ករយៈពេលចំនួន **៧ថ្ងៃ** ហើយអ្នកដំណើរបរទេសត្រូវទទួលការយកសំណាកលើកទី២ ដោយធ្វើតេស្តដោយម៉ាស៊ីន PCR នៅថ្ងៃទី៦។ ក្នុងករណីលទ្ធផលបញ្ជាក់ថា វិជ្ជមានកូវីដ-១៩ ត្រូវបញ្ជូនទៅព្យាបាល។ ក្នុងករណីលទ្ធផលបញ្ជាក់ថា អវិជ្ជមានកូវីដ-១៩ ត្រូវបញ្ចប់ការធ្វើចត្តាឡីស័កនៅថ្ងៃទី៧។

**៦.- អ្នកដំណើរគ្រប់ប្រភេទ ដែលមិនបានចាក់វ៉ាក់សាំងកូវីដ-១៩ ឬមិនទាន់ចាក់វ៉ាក់សាំងបានពេញលេញ**

ចំពោះក្រុមអ្នកដំណើរដែលបានរៀបរាប់ខាងលើ ករណីមិនទាន់បានចាក់វ៉ាក់សាំងកូវីដ-១៩ ឬចាក់វ៉ាក់សាំងមិនទាន់បានពេញលេញ ការអនុវត្តលក្ខខណ្ឌធ្វើដំណើរ ត្រូវអនុវត្តដូចបានរៀបរាប់ខាងលើ ប៉ុន្តែរយៈពេលនៃការធ្វើចត្តាឡីស័កគឺចំនួន **១៤ថ្ងៃ** និងត្រូវមានឯកសារកក់សណ្ឋាគារសម្រាប់ការធ្វើចត្តាឡីស័ក **នៅសណ្ឋាគារណាមួយ (ដូចមានបង្ហាញក្នុងឧបសម្ព័ន្ធទី ១)**។ ក្នុងករណីពុំមាន ត្រូវត្រៀមសាច់ប្រាក់ចំនួន ២ ០០០ ដុល្លារអាមេរិក (សម្រាប់អ្នកដំណើរបរទេស) ដើម្បីតម្កល់នៅច្រកចូលកម្ពុជា សម្រាប់ជានាចំណាយទាំងអស់ពាក់ព័ន្ធនឹងការធ្វើចត្តាឡីស័ក ក្នុងអំឡុងពេលធ្វើចត្តាឡីស័កនៅពេលមកដល់កម្ពុជា។

អ្នកដំណើរ ត្រូវសហការឱ្យមន្ត្រីសុខាភិបាលធ្វើការយកសំណាក ហើយក្រោយពេលទៅដល់ទីតាំងចត្តាឡីស័កនៅសណ្ឋាគារ ឬទីតាំងដែលកំណត់ដោយក្រសួងសុខាភិបាល អ្នកដំណើរនឹងត្រូវរង់ចាំលទ្ធផលៈ

- ក្នុងករណីលទ្ធផលតេស្តលើកទី១ ដោយប្រើ Rapid Test (នៅពេលមកដល់កម្ពុជា) វិជ្ជមានកូវីដ-១៩ អ្នកដំណើរនឹងត្រូវបញ្ជូនទៅព្យាបាលនៅតាមមណ្ឌលព្យាបាល
- ក្នុងករណីលទ្ធផលតេស្តលើកទី១ ដោយប្រើ Rapid Test អវិជ្ជមានកូវីដ-១៩ អ្នកដំណើរត្រូវបន្តធ្វើចត្តាឡីស័ករយៈពេលចំនួន **១៤ថ្ងៃ** ហើយអ្នកដំណើរត្រូវទទួលការយកសំណាកលើកទី២ ដោយធ្វើតេស្តដោយម៉ាស៊ីន PCR នៅថ្ងៃទី១៣នៃការធ្វើចត្តាឡីស័ក។ ក្នុងករណីលទ្ធផលបញ្ជាក់ថា វិជ្ជមានកូវីដ-១៩ ត្រូវបញ្ជូនទៅព្យាបាល។ ក្នុងករណីលទ្ធផលបញ្ជាក់ថា អវិជ្ជមានកូវីដ-១៩ ត្រូវបញ្ចប់ការធ្វើចត្តាឡីស័ក នៅថ្ងៃទី១៤។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមអ្នកដំណើរបរទេស ដែលមានការធានា ឬការអញ្ជើញ មន្ត្រីការទូតបរទេស និងមន្ត្រីមន្ត្រីអនុវត្តគម្រោងសហប្រតិបត្តិការផ្លូវការ ដែលកាន់ទិដ្ឋាការការទូតប្រភេទ A និងទិដ្ឋាការផ្លូវការប្រភេទ B និងអ្នកដំណើរជាមន្ត្រីរាជការ ឬអ្នកដំណើរជាជនជាតិខ្មែរ ដែលប្រើប្រាស់លិខិតឆ្លងដែនកម្ពុជា ឬលិខិតឆ្លងដែនបរទេស និងជនបរទេសទូទៅ មេត្តាជ្រាប និងចូលរួមសហការប្រកបដោយការទទួលខុសត្រូវ ដើម្បីរួមគ្នាអនុវត្តវិធានការប្រយុទ្ធនឹងជំងឺកូវីដ-១៩ របស់រាជរដ្ឋាភិបាលកម្ពុជាឱ្យមានប្រសិទ្ធភាពខ្ពស់។

**សេចក្តីជូនដំណឹងនេះ នឹងអនុវត្តចាប់ពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ នេះតទៅ។** ចំពោះអ្នកដំណើរដែលមកដល់កម្ពុជាមុនថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ និងកំពុងធ្វើចត្តាឡីស័ក ក៏អាចទទួលបានការសម្រួលដូចគ្នាដែរ ក្នុងករណីទទួលបានការចាក់វ៉ាក់សាំងកូវីដ-១៩ ពេញលេញ, មានឯកសារគ្រប់គ្រាន់ និងបំពេញរាល់លក្ខខណ្ឌខាងលើ ។

ថ្ងៃសៅរ៍ ១០កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធាន**
**គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩**

**ម៉ម ប៊ុនហេង**

# ឧបសម្ព័ន្ធទី១

# បញ្ជីសណ្ឋាគារដែលទទួលកក់សេវាធ្វើចត្តាឡីស័ក

| ល.រ. | ឈ្មោះសណ្ឋាគារ | គេហទំព័រ |
| --- | --- | --- |
| ១ | Sokha Phnom Penh Residence | https://sokhahotels.com.kh/phnompenh/ |
| ២ | Courtyard by Marriott | https://www.marriott.com/hotels/travel/pnhcy-courtyard-phnom-penh/ |
| ៣ | Raffles Hotel Le Royal | https://www.raffles.com/phnom-penh/ |
| ៤ | Sofitel Phnom Penh Phokeethra | https://www.sofitel-phnompenh-phokeethra.com/ |
| ៥ | Himawari | http://www.himawarihotel.com/ |

# ឧបសម្ព័ន្ធទី២
# គំរូ លិខិតបញ្ជាក់លើការធានា
# សម្រាប់អ្នកចាក់វ៉ាក់សាំងជូសម្ពូលដ្ឋានបានពេញលេញ

## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

## លិខិតបញ្ជាក់លើការធានា

VALIDATION CERTIFICATE ON GUARANTEE

លេខវិញ្ញាបនបត្រ(No.):**000000012**

## រាជរដ្ឋាភិបាលកម្ពុជា

សូមបញ្ជាក់ថាក្រុមហ៊ុនឈ្មោះ **MY KHMER FARM CO., LTD.**
ដែលមានអាសយដ្ឋាន **#292, St 789, Tuol Kork, Phnom Penh**
ជាមួយនិងលេខទូរស័ព្ទក្រុមហ៊ុន **+85592888296** បានធានាទទួលខុសត្រូវទាំងស្រុង លើចំណាយទាំងអស់ពាក់ព័ន្ធនឹងការធ្វើចត្តាឡីស័ក និង/ឬការព្យាបាល ក្នុងករណីដែលអ្នកដំណើរខាងក្រោមនេះ ត្រូវបានតម្រូវដោយស្ថាប័នមានសមត្ថកិច្ចរបស់កម្ពុជាឱ្យធ្វើចត្តាឡីស័ក និង/ឬធ្វើការព្យាបាលជំងឺកូវីដ-១៩ នៅពេលធ្វើដំណើរមកដល់កម្ពុជា។ ព័ត៌មានអ្នកដំណើរមានដូចខាងក្រោម៖

ឈ្មោះ **DARA SOK** — កើតថ្ងៃទី **02 January 1990**
តួនាទី **CEO** — លិខិតឆ្លងដែនលេខ **H3234324**

## The Royal Government of Cambodia

Certifies that **MY KHMER FARM CO., LTD.** located at **#292, St 789, Tuol Kork, Phnom Penh** with company's phone number **+85592888296**, has pledged to be entirely responsible for paying all expenses related to quarantine and/or treatment, should the below traveler is required by Cambodia's authorized institutions to quarantine and/or receive Covid-19 treatment upon arrival in Cambodia. The information of the traveler is as detailed below:

Name **DARA SOK** — Born on **02 January 1990**
Position **CEO** — Passport No. **H3234324**

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០២១
Phnom Penh, September 27, 2021

បានចាក់វ៉ាក់សាំងពេញលេញ៖ [AstraZeneca, AB] AZD1222 Vaxzevria
Fully vaccinated: [AstraZeneca, AB] AZD1222 Vaxzevria

# ឧបសម្ព័ន្ធទី៣
## គំរូ លិខិតបញ្ជាក់លើការអញ្ជើញ
## សម្រាប់អ្នកចាក់វ៉ាក់សាំងដូសមូលដ្ឋានបានពេញលេញ

សាម៉ីខ្លួន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

### លិខិតបញ្ជាក់លើការអញ្ជើញ

VALIDATION CERTIFICATE ON INVITATION

លេខវិញ្ញាបនបត្រ(No.):**000000012**

### រាជរដ្ឋាភិបាលកម្ពុជា

សូមបញ្ជាក់ថាក្រុមហ៊ុនឈ្មោះ **MY KHMER FARM CO., LTD.**
ដែលមានអាសយដ្ឋាន **#292, St 789, Tuol Kork, Phnom Penh**
ជាមួយនឹងលេខទូរស័ព្ទក្រុមហ៊ុន **+85592888296** បានអញ្ជើញអ្នកដំណើរដូចខាងក្រោម៖

ឈ្មោះ **DARA SOK** កើតថ្ងៃទី **02 January 1990**
តួនាទី **CEO** លិខិតឆ្លងដែនលេខ **H3234324**

អ្នកដំណើរខាងលើនឹងទទួលខុសត្រូវដោយខ្លួនឯងទាំងស្រុងក្នុងការចំណាយទាំងអស់ពាក់ព័ន្ធនឹងការព្យាបាល ក្នុងករណីដែលអ្នកដំណើរខាងលើនេះមានការឆ្លងជំងឺកូវីដ-១៩ និងរាល់ការចំណាយទាំងអស់ពាក់ព័ន្ធនឹងការធ្វើចត្តាឡីស័ក ក្នុងករណីដែលអ្នកដំណើរនេះត្រូវបានតម្រូវដោយស្ថាប័នមានសមត្ថកិច្ចរបស់កម្ពុជាឱ្យធ្វើចត្តាឡីស័ក។

### The Royal Government of Cambodia

Certifies that **MY KHMER FARM CO., LTD.** located at **#292, St 789, Tuol Kork, Phnom Penh** with company's phone number **+85592888296** has invited the following traveler:

Name **DARA SOK** Born on **02 January 1990**
Position **CEO** Passport No. **H3234324**

*The above traveler will entirely be responsible for paying all expense related to treatment should* he/she test positive for Covid-19 and all expenses related to quarantine should he/she be required by Cambodia's authorized institution to quarantine.

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០២១
Phnom Penh, September 27, 2021



បានចាក់វ៉ាក់សាំងពេញលេញ៖ [AstraZeneca, AB] AZD1222 Vaxzevria
Fully vaccinated: [AstraZeneca, AB] AZD1222 Vaxzevria